**សុន្ទរកថាស្វាគមន៍**

ឆាំង យុ

នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

ក្នុងពិធីបើកសន្និសីទលើកទី១ ស្តីពី «អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍»

ថ្ងៃចន្ទ ១៣កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ត្រូវនឹងថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤

-សូមគោរព **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់!

-សូមគោរព ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល

-សូមគោរព លោកជំទាវ អាលីស វ៉ៃរីមូ ឌីរីទូ អគ្គលេខាធិការរង និង ជាទីប្រឹក្សាពិសេស របស់អង្គការសហប្រជាជាតិ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍

-សូមគោរព លោកជំទាវ បេិត វ៉ាន់សាក់ អគ្គរដ្ឋទូតសហរដ្ឋអាមេរិក ការិយាល័យយុត្តិធម៌ព្រហ្មទណ្ឌសកល នៃក្រសួងការបរទេសសហរដ្ឋអាមេរិក

-សូមគោរព ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ

-សូមគោរព អ៊ំ ពូ មីង ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងប្អូនៗដែលជាអ្នកស្រាវជ្រាវវ័យក្មេង ជាទីគោរព និងជាទីស្នេហា!

ខ្ញុំបាទ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងជាស្ថាបនិកព្រះរាជបណ្ណាល័យហ្លួងម៉ែ សូមគោរពស្វាគមន៍សន្និសីទលើកទី១ ក្រោមប្រធានបទ **«អនាគតកម្ពុជាដោយគ្មានអំពើប្រល័យពូជសាសន៍»**។ ទូលព្រះបង្គំ ខ្ញុំបាទសូមថ្លែងអំណរព្រះគុណ និងអំណរគុណយ៉ាងជ្រាលជ្រៅ **ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**, **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និង សុភមង្គល, **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងកងកម្លាំង



Documentation Center of Cambodia
Mansion 11, Street 256, Phnom Penh, Cambodia ♦ dccam@online.com.kh ♦ www.dccam.org
'...a society cannot know itself if it does not have an accurate memory of its own history.'
— SINCE 1995 —

ប្រដាប់អាវុធ មានជាអាទិ៍ នាយទាហាន និងពលទាហាននៃកងយោធពលខេមរភូមិន្ទ និងនាយនគរបាល ពលនគរបាលជាតិ។ ខ្ញុំបាទសូមដឹងគុណដល់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ ដែលតែងតែផ្តល់ជំនួយគាំទ្រយ៉ាងខ្ជាប់ខ្ជួនមកមជ្ឈមណ្ឌលឯកសារកម្ពុជា។ សន្និសីទលើកទី១នេះ មិនអាចប្រព្រឹត្តទៅបានឡើយប្រសិនបើពុំមានការគាំទ្រទាំងអស់ខាងលើនេះទេ។

ខ្ញុំបាទ សូមគោរពអរគុណយ៉ាងក្រៃលែង **ឯកឧត្តមនាយឧត្តមសេនីយ៍ ម៉ៅ សុផាន់** មេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក ដែលអនុញ្ញាតឲ្យខ្ញុំបាទ ប្រើប្រាស់ទីតាំង **សាលយុត្តិតេជោ** ដ៏មានសារសំខាន់ដើម្បីរៀបចំសន្និសីទក្នុងថ្ងៃនេះ។ ការគាំទ្រនិងការជួយជ្រោមជ្រែងដ៏សស្រាក់សស្រាំពីសំណាក់ឯកឧត្តមនាយឧត្តមសេនីយ៍ គឺពិតជាមានសារសំខាន់យ៉ាងធំធេងក្នុងការជំរុញឲ្យសន្និ សីទនេះប្រព្រឹត្តទៅបានយ៉ាងល្អប្រសើរ។

សមត្ថភាពរបស់កម្ពុជាក្នុងការសម្រេចបាននូវអនាគតមួយដោយគ្មានអំពើប្រល័យពូជសាសន៍ គឺពឹងផ្អែកយ៉ាងសំខាន់ទៅលើភាពអង់អាចមោះមុតរបស់កម្ពុជា ក្នុងការប្រឈមតទល់ជាមួយនឹងប្រវត្តិសាស្ត្ររបស់ខ្លួន ព្រមទាំងប្រែក្លាយមេរៀនជាគំរូទាំងអស់នេះ ទៅជាយុទ្ធសាស្ត្រប្រកបដោយអត្ថន័យសម្រាប់អនាគតកាល។ សន្និសីទលើកទី១នេះ គឺជាជំហានដ៏ចាំបាច់មុតមាំឈានទៅសម្រេចបានដំណើរដ៏វែងឆ្ងាយមួយ។

ក្រុមការងាររៀបចំសន្និសីទ មានគោលបំណងបង្កើតជាសហគមន៍អន្តរកាលមួយ ដោយប្រមូលផ្តុំនូវអ្នកជំនាញផ្នែកសិទ្ធិមនុស្ស និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ នៅក្នុងសង្គមក្រោយជម្លោះដែលអាចចែករំលែកការយល់ឃើញប្រកបដោយភាពច្នៃប្រឌិត និងការអនុវត្តប្រសើរបំផុតឲ្យរួមគ្នាកសាងនូវសន្តិភាព ប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជានិងសង្គមដទៃផ្សេងទៀត។ សន្និសីទក្នុងថ្ងៃនេះ គឺជាសន្និសីទដំបូងបង្អស់ ដែលនឹងដើរតួនាទីជាមូលគ្រឹះសម្រាប់បណ្តាញទំនាក់ទំនងនេះ។

ជាថ្មីម្តងទៀត ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា, ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ, ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ, ឯកឧត្តមលោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា ដែលបានចំណាយពេលចូលរួមនៅក្នុងព្រឹត្តិការណ៍ដ៏មានសារសំខាន់នាថ្ងៃនេះ។ ខ្ញុំបាទទន្ទឹងរង់ចាំត្រងត្រាប់ស្តាប់ការចែករំលែក ទស្សនៈយល់ឃើញ និងមតិយោបល់ដ៏ថ្លៃថ្លារបស់សម្តេច ឯកឧត្តមលោកជំទាវ លោក-លោកស្រី អ្នកនាងកញ្ញា។